ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ
-សំណុំរឿងព្រហ្មទណ្ឌលេខ: ២៧២
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤
-សំណុំរឿងជំនុំជម្រះលេខ: ៣៦៧
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤
-សាលក្រមព្រហ្មទណ្ឌលេខ: ៥៤ (ខ)
ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

-កាលបរិច្ឆេទបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤។
-កាលបរិច្ឆេទប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។

**ដោយសមាសភាពចូលរួម ៖**

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក ចៅក្រុមប្រឹក្សាជំនុំជម្រះ
-លោកស្រី ចៅក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ជាតំណាងអយ្យការ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ

**មេធាវី**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២៧២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមាន៖

**ជនជាប់ចោទ៖**

១-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួនរស់នៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] សន (រស់) ម្តាយឈ្មោះ ស្រី (រស់) ប្រពន្ធឈ្មោះ [redacted] ផាត មានកូន ០៣ នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន" ។ (ក្នុងឃុំ)

២-ឈ្មោះ [redacted] ស្លា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិប្រ [redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] ផាន (រស់) ម្តាយឈ្មោះ [redacted] រឿន (រស់) នៅលីវ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន "គ្មាន" ។ (ក្រៅឃុំ)



Scanned with CamScanner

ត្រូវជាប់ចោទពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំ គ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៨ និង៣០ នាទី នៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ មានករណីលួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ) មួយបានកើតឡើងដែលប្រព្រឹត្តឡើងដោយឈ្មោះ [redacted]សុក និងឈ្មោះ [redacted] ស្នា។ ឈ្មោះ [redacted] សុក បានសារភាពថា កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៥ និង០០នាទី ខ្លួនកំពុងនៅផ្ទះ ស្រាប់តែឈ្មោះ ស្នា បានតេទូរស័ព្ទមកប្រាប់ថា អាសុកទៅលួចម៉ូតូជាមួយអញ ហើយខ្លួនសួរថាទៅលួចនៅឯណា ឈ្មោះ ស្នា ឆ្លើយថាទៅលួច នៅអូរធំ ហែងមកយកអញនៅកន្លែងចាស់ ភ្លាមនោះខ្លួនក៏បានជិះម៉ូតូម៉ាកសេ១២៥ ចាស់ មានតែឆ្អឹង គ្មានផ្លាកលេខ ជិះទៅជួបឈ្មោះ ស្នា នៅខាងជើងភូមិត្រពាំងព្រីង ពេលទៅដល់ឈ្មោះ ស្នា ឈរកាន់ស្រាបៀរហ្គេនស៊ើក កន្លះកេស ដាក់ថង់ខ្មៅ ភ្លាមនោះឈ្មោះ ស្នា បានយកដាវដែលលាក់ក្បែរនោះយកមកដាក់ក្រោមកែបម៉ូតូ ខ្លួនក៏មានដាវមួយដែរ។ បន្ទាប់មកខ្លួនបានជិះម៉ូតូឌុបឈ្មោះ ស្នា ទៅកន្លែងស្ងាត់ហើយចូលទៅក្នុងចំការស្វាយចន្ទី ដែលមានតែខ្ទមតែគ្មានមនុស្សនៅ ហើយខ្លួនបាននាំគ្នាអង្គុយផឹកស្រាបៀរប្រហែលមួយម៉ោង ពេលផឹកស្រាអស់ ទើបពួកខ្លួនជិះម៉ូតូទៅមុខទៀត ខ្លួនជាអ្នកបើក លុះដល់ចំណុចអូរធំ ភូមិដងក្តារ ម៉ោងប្រហែល១៧ជាង ឈ្មោះ ស្នា បានចុះពីលើម៉ូតូទៅពួននៅក្នុងចំការចន្ទីក្បែរផ្លូវ ហើយខ្លួនជិះម៉ូតូទៅមុខទៀត លុះដល់ម៉ោងប្រហែល១៨ល្ងាច ខ្លួនបានឃើញម៉ូតូមួយគ្រឿងមានមនុស្សស្រីពីរនាក់ ជិះឌុបគ្នា ឆ្លងហួសស្ពានអូរធំ ចម្ងាយប្រហែល១០០ម៉ែត្រ ខ្លួនក៏ជិះម៉ូតូដេញតាម ហើយដណ្តើមសោរម៉ូតូពីមនុស្សស្រីនោះបាន ហើយទុកម៉ូតូខ្លួនចោលកន្លែងនោះ ដោយជិះម៉ូតូរបស់គេដែលយកបានជិះឡើងមកដងក្តារវិញ ពេលមកដល់កន្លែងឈ្មោះ ស្នា បានចុះពួនហើយខ្លួនបានស្រែកហៅឲ្យចេញហើយឈ្មោះ ស្នា បានរត់មកឡើងជិះម៉ូតូ ខ្លួនក៏បានបើករត់គេចចូលផ្លូវចំបក់ធំ ភូមិដងក្តារឈ្មោះ ស្នា បានចុះដើរហើយប្រាប់ខ្លួនថាជិះម៉ូតូនេះយកទៅទុកនៅផ្ទះឯងទៅ ពេលនោះខ្លួនជិះម្នាក់ឯងទៅផ្ទះភូមិទក់ ឃុំក្រយា បានទុកម៉ូតូក្នុងផ្ទះ។ លុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៨ និង០០នាទី ហូបបាយរួច ខ្លួនបានចាប់ផ្តើមដោះអាវម៉ូតូ ពណ៌ខ្មៅ ឆ្នាំ២០២២ ដែលលួចបាននេះដូរដាក់អាវពណ៌សវិញ ដូរផ្លាកលេខ ដូរកង់ទាំងពីរ ដូរកែប និងដោះដូរ គ្រឿងខ្លះៗទៀត មិនទាន់បានជិះទៅណាទេ។ លុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៥ និង០០នាទី ស្រាប់តែសមត្ថកិច្ចបានមកដល់ផ្ទះឃាត់ខ្លួនតែម្តង។ ខ្លួនបានធ្វើសកម្មភាពលួចចំនួន០៤ដងមកហើយ។ ដោយកន្លងមកនៅអំឡុងឆ្នាំ២០២២ ខ្លួនបានឃុបប្រពន្ធទៅលួចម៉ូតូនៅចំការដំឡូងខាងត្បូងឃុំក្រយា ដោយលួចបានម៉ូតូម៉ាកស្នាក់ ពណ៌ខ្មៅ ចំនួន០១គ្រឿង យកទៅទុកក្នុងផ្ទះខ្លួននៅភូមិទក់។ ៥ថ្ងៃក្រោយ មកខ្លួនបានឃុបប្រពន្ធយកម៉ូតូទៅលក់ នៅឃ្លាំងម៉ូតូស្រុកបារាយណ៍ បានតម្លៃ ៥០០,០០០ (ហាសិបម៉ឺន) រៀល។ នៅឆ្នាំ២០២៣ ឈ្មោះ ស្នា បានប្រាប់ខ្លួននៅហាងកាហ្វេកំពង់ថ្ម ថាយប់នេះយើងលួចកាបូបនៅផ្សារកំពង់ថ្ម។ លុះម៉ោងប្រហែល៤ទាបភ្លឺ ឈ្មោះស្នា បានជិះម៉ូតូមកយកខ្លួនទៅរកឆក់កាបូបលុយគេនៅមុខសាលារៀនកំពង់ថ្ម ដោយឆក់បានកាបូបពណ៌ខ្មៅមួយ ហើយជិះមកផ្ទះវិញចែកលុយគ្នា ដោយខ្លួនបានលុយចំនួន ២៥០,០០០ (ម្ភៃប្រាំម៉ឺន) រៀល។ នៅថ្ងៃខែមិនចាំឆ្នាំ២០២៣ដដែល ខ្លួនបានជិះម៉ូតូឌុបឈ្មោះ ស្នា មកពីភូមិថ្មសំលៀង ក៏បានជួបមនុស្សស្រីពីរនាក់ជិះម៉ូតូឌុបគ្នា ពេលនោះខ្លួនបានឈប់ម៉ូតូ ឈ្មោះ ស្នា បានឲ្យខ្លួនចុះពួនក្នុងព្រៃចន្ទី រួចឈ្មោះ ស្នា បានជិះម៉ូតូដេញតាមពីក្រោយមួយសន្ទុះក្រោយមកឈ្មោះ ស្នា បានជិះម៉ូតូមកវិញមានកាន់កាបូបស្ពាយមួយ បន្ទាប់មកពួកខ្លួនបានជិះម៉ូតូមកភូមិដងក្តារវិញ ដល់ក្រោយភូមិស្ងាត់ពួកខ្លួនបានឈប់ម៉ូតូចែកលុយគ្នា ឈ្មោះ ស្នា បានឲ្យខ្លួនចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល ខ្លួនមិនដឹងថាលុយក្នុងកាបូបនោះមានចំនួន



Scanned with CamScanner

ប៉ុន្មានទេ។ បន្ទាប់មកនៅថ្ងៃខែមិនចាំឆ្នាំ២០២៣ ខ្លួនបានជិះម៉ូតូទៅឌុបឈ្មោះ ស្លា នៅខាងជើងភូមិក្រយាទៅភូមិបាក់ស្លា ពេលឆ្លងស្ពានមានផ្ទះអ្នកលក់អង្ករមួយនៅជិត ដល់ផ្សារបាក់ស្លា ពេលនោះឈ្មោះ ស្លា បានកាន់ដាវចូលទៅក្នុងតូបលក់អង្ករគម្រាមគេយកកាបូបរួចចេញមកវិញ ខ្លួនក៏បានឌុបឈ្មោះ ស្លា ចេញមកវិញជិតដល់ស្ពានក៏ជួបប៉ូលីស ពេលនោះឈ្មោះ ស្លា បានប្រាប់ឱ្យខ្លួនចុះដើរសិន ចំណែកឈ្មោះ ស្លា បានជិះម៉ូតូម្នាក់ឯង។ ពេលនោះខ្លួនអត់ហ៊ានដើរឆ្លងស្ពានទេ ចុះដើរផ្លូវកាត់ឆ្លងស្ទឹង រួចឡើងជិះម៉ូតូឌុបគ្នាមកដល់កន្លែងស្ងាត់ ស្ថិតនៅភូមិដងក្តារ ឈ្មោះ ស្លា ហុចលុយឱ្យខ្លួនចំនួន ៣៥០,០០០ (សាមសិបប្រាំម៉ឺន) រៀល។ លុះដល់ថ្ងៃខែមិនចាំឆ្នាំ២០២៣ដដែល ខ្លួនជាមួយឈ្មោះ រ័ត្ន ហៅធី ភេទប្រុស អាយុប្រហែល២៥ឆ្នាំ នៅភូមិត្រពាំងព្រីង ឃុំក្រយា បានបបួលគ្នាជិះម៉ូតូទៅគាស់តូបទូរស័ព្ទគេនៅជិតផ្សារកំពង់ថ្ម នៅម៉ោង២យប់ ដោយពួកខ្លួនចូលលួចគាស់ បានទូរស័ព្ទដៃចំនួន១០គ្រឿង មានម៉ាកអិនចុចពិលចំនួន ០៩គ្រឿង និងអាយហ្វូនជាប់អាយក្លោត ០១គ្រឿង។ នៅថ្ងៃខែមិនចាំឆ្នាំ២០២៣ ឈ្មោះ រ័ត្ន ហៅធី បានជិះម៉ូតូមកផ្ទះខ្លួន បបួលខ្លួនទៅរកប្លន់ម៉ូតូគេនៅផ្លូវភូមិខ្វែក ឃុំកំពង់ថ្ម ពេលនោះខ្លួនបានប្រាប់ថាមិនទៅទេ គ្មានអ្នកចាំផ្ទះ ព្រោះប្រពន្ធទៅលេងឪពុកនៅភូមិដងក្តារ ឈ្មោះ រ័ត្ន ហៅធី បានជិះម៉ូតូចេញទៅបាត់។ លុះព្រឹកឡើងឈ្មោះ រ័ត្ន ហៅ ធី បានជិះម៉ូតូម៉ាកសង់ មិនស្គាល់សេរី ព្រោះបិទឆ្នូតពីលើតែម ពណ៌ខ្មៅ មកដល់ផ្ទះខ្លួននិយាយប្រាប់ថាយប់មិញវាលួចម៉ូតូគេនៅភូមិខ្វែកបានចំនួន ០១គ្រឿង។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: **៣៣៨/២០២៥** ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-**បានឃើញ** ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ: **៣០១០/២០២៤** ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

-**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ: **៤៦០ឥ.ទ្រ** ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

**នាពេលសវនាការ**

| | |
|---|---|
| -ជនជាប់ចោទឈ្មោះ [redacted] សុភ | **វត្តមាន** |
| -ជនជាប់ចោទឈ្មោះ [redacted] ស្លា | **អវត្តមាន** |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភូឡុង់ | **វត្តមាន** |
| -ជនរងគ្រោះឈ្មោះ [redacted] ស្រីចាំ | **វត្តមាន** |
| -សាក្សីឈ្មោះ [redacted] ចែ | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] ហុន | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] ផាត | **វត្តមាន** |
| -សាក្សីឈ្មោះ [redacted] សារ៉ែន | **វត្តមាន** |
| -សាក្សីឈ្មោះ [redacted] ឈាង | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] ញឿន | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] មី | **វត្តមាន** |
| -សាក្សីឈ្មោះ [redacted] តឿន | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] ណោម | **អវត្តមាន** |
| -សាក្សីឈ្មោះ [redacted] ចក់ | **អវត្តមាន** |



Scanned with CamScanner

-សាក្សីឈ្មោះ [redacted] ទិត អវត្តមាន

-សាក្សីឈ្មោះ [redacted] សុភា អវត្តមាន

-សាក្សីឈ្មោះ [redacted] គេង អវត្តមាន

-មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] សារិទ្ធ អវត្តមាន

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វត្តមាន

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វត្តមាន

## ដំណើរការសួរដេញដោលក្នុងពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុភ បានឆ្លើយនាពេលសវនាការថា៖ កាល ពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៤ រូបខ្លួនបាន តេទូរស័ព្ទទៅអាស្នា ដោយបបួលវាទៅយកម៉ូតូនៅម្តុំស្ពានអូរធំ ស្ថិតនៅភូមិ ដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដោយណាត់ជួបគ្នាម៉ោងពារសៀលជាង ហើយពួកខ្លួនក៏បានជួបគ្នានៅ ក្នុងចម្ការចន្ទីរបស់គេដោយមានខ្ទមចាស់បាក់បែក ពេលនោះពួកខ្ញុំផឹកស្រាបៀរហ្គេនស៊ើកអស់ប្រហែលជិតកន្លះកំ នាំគ្នាជិះម៉ូតូមកអូរដោយពេលនោះ ពួកខ្លួនបានដាក់ដាវប្រវែងប្រហែល៤តឹក ចំនួន២ដើម ដាក់ក្រោមកែបម៉ូតូរបស់ ខ្លួន ពេលនោះជិះជិតដល់អូរធំ ស្រាប់តែមានស្រី១ពីរនាក់ក្មេងម្នាក់អាយុខ្ទង់១៨ឆ្នាំ ចាស់ អាយុខ្ទង់២៨ឆ្នាំ ជិះម៉ូតូ ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ផលិតឆ្នាំ២០២២ មិនចាំផ្លាកលេខតាមពីក្រោយពេលនោះពួកខ្លួនក៏ជិះម៉ូតូដេញ ហើយ ខ្លួនក៏បានដកដាវចេញអោយពួកគាត់ចុះ ពេលនោះពួកគាត់ក៏ចុះ ចំណែកអាស្នាវារត់ពួននៅក្នុងដើមចន្ទី ។ នៅពេល ដែលបានម៉ូតូនេះបានខ្លួនក៏បានទុកម៉ូតូចាស់របស់ខ្លួននៅក្បែរផ្លូវយកម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ផលិត២០២២ មិនចាំផ្លាកលេខជិះមកក្រោយទៅផ្ទះវិញដោយរូបខ្លួនជាអ្នកឌុប, ចំណែកឯអាស្នាជាអ្នកជិះពីក្រោយ។ លុះស្អែក ឡើងខ្លួនទិញខោអាវម៉ូតូតាមonline ដោយទិញបានអាវក៏បានដូរអាវពណ៌ខ្មៅ មកដាក់ពណ៌ស កែបដូរកង់ទាំង ពីរទៀត និងដូរបូមម៉ូតូទាំងពីរទៀតដើម្បីកុំឱ្យគេចំណាំ ស្រាប់តែនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ សមត្ថកិច្ចចុះមក ចាប់ខ្លួនដល់ផ្ទះតែម្តង ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចម៉ូតូឆក់កាបូបលុយ និងលួចទូរស័ព្ទ ចំនួន០៧លើក និងជាមួយប្រពន្ធរបស់ខ្លួនចំនួន១លើក មួយឈ្មោះ [redacted] ស្នា ចំនួន០៤លើក ជាមួយឈ្មោះរ័ត្ន ហៅ ធី ចំនួន២លើក និងបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ស្នា ចំនួន០៤លើក:ទី១មិនចាំថ្ងៃខែឆ្នាំ ទី១មិនចាំថ្ងៃខែឆ្នាំនោះទេ ដោយពេលនោះខ្លួនជាអ្នកឌុប អាស្នា ហើយអាស្នាជាអ្នកឆក់កាបូប លុយនៅមុខសាលារៀន សាលារៀនមិនចាំឈ្មោះ បានលុយចំនួន ៦០០.០០០ (ហុកសិប ម៉ឺន)រៀល។ ទី២ មិនចាំថ្ងៃខែឆ្នាំ ដោយពេលនោះខ្លួនជាអ្នកឌុបអាស្នា ហើយអាស្នាជាអ្នកឆក់កាបូបនៅខាង ក្រោយ ឃុំក្រយា តំបន់នោះស្ងាត់ បានលុយចំនួន ៨០០.០០០ (ប៉ែតសិបម៉ឺន) រៀល។ ទី៣ មិនចាំថ្ងៃខែឆ្នាំ ដោយពេលនោះ អាស្នា បានយកដាវទៅក្នុងអ្នកលក់អង្ករនៅម្តុំបាក់ស្នាដោយខ្លួនជាអ្នកបិទគូទ បានលុយចំនួន ៧០០.០០០ (ចិតសិប ម៉ឺន)រៀល និងទី៤ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ខ្លួននិងអាស្នា បានទៅយកម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ផលិត ឆ្នាំ២០២២ មិនចាំផ្លាកលេខ នៅម្តុំស្ពានអូរធំស្ថិតនៅភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ហើយក៏ត្រូវបាន មត្តកិច្ចឃាត់ខ្លួនតែម្តង។ សម្មភាពលួចទូរស័ព្ទជាមួយឈ្មោះរ័ត្ន ហៅ ធី ចំនួន០២លើក:ទី១មិនចាំថ្ងៃខែឆ្នាំ រូបខ្លួន : រ័ត្ន ហៅ ធី បាននាំគ្នាទៅគាស់ទូរស័ព្ទនៅផ្សារកំពង់ថ្ម បានចំនួន១០គ្រឿង និងទី២ រូបខ្លួន និងឈ្មោះរ័ត្ន និងឈ្មោះ ហៅ ធី បាននាំគ្នាទៅលួចទូរស័ព្ទនៅក្រយាដងក្តារ ប៉ុន្តែពេលមកដល់កន្លែងក៏ឃើញមនុស្សក៏ពួកខ្លួនជិះម៉ូតូបកមក ក្រោយវិញទៅ។ សកម្មភាពលួចម៉ូតូជាមួយប្រពន្ធ ចំនួន០១លើក: : ទី១ ខ្ញុំនិងប្រពន្ធឈ្មោះសិនផាត បានលួចម៉ូតូមិន ចាំម៉ាកសល់តែឆ្អឹង ដោយគេទុកចោលនៅឃុំក្រយា ដោយលក់បានលុយចំនួន៥០០.០០០(ហាសិបម៉ឺន) រៀល។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] **ស្នា** បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្ញុំបាទសុំ បដិសេធការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រោះខ្ញុំបាទមិនបានធ្វើសកម្មភាពប្លន់យកម៉ូតូជាមួយឈ្មោះ [redacted] សុក នោះទេ ហើយក៏មិនដែលស្គាល់ឈ្មោះនេះដែរ។ កាលពីថ្ងៃកើតហេតុ គឺនៅថ្ងៃទី១៦ និងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ ខ្ញុំបាទជាប់ធ្វើម្ហូបការគេ នៅស្រុកប្រាសាទសំបូរ ជាមួយបងធម៌ឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ៤៧ឆ្នាំ រស់នៅ ភូមិត្រពាំងសិលា ឃុំ ត្រពាំងសិលា ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ និងអ្នកផ្សេងទៀតដែលខ្ញុំបាទមិនស្គាល់។ នៅថ្ងៃចូលរោង គឺនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ខ្លួនបានហាន់សាច់ ហាន់បន្លែ សម្រាប់ថ្ងៃគេចូលរោង ដោយខ្ញុំបាទ បានចេញពីផ្ទះតាំងពីព្រឹក រហូតដល់ល្ងាចបានធ្វើម្ហូបចប់ហើយក៏បានដេកនៅរោងការតែម្តង។ លុះស្អែកឡើងខ្ញុំបាទធ្វើម្ហូបមួយព្រឹកទៀត ហើយពេលថ្ងៃក៏ត្រឡប់មកវិញ។ខ្ញុំបាទសូមបញ្ជាក់ថាមិនស្គាល់ឈ្មោះ [redacted] សុក នោះទេហើយក៏មិនដែលមានទំនាស់ជាមួយគ្នានោះដែរ សមត្ថកិច្ចក៏មិនបានដកហូតអ្វីនោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អ៊ូឡុង** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២៤ វេលាម៉ោង៥ ទៅម៉ោង៦ ល្ងាច កូននាងខ្ញុំមានឈ្មោះ [redacted] ស្រីង៉ា ភេទស្រី អាយុ១៣ បានជិះម៉ូតូហុងដាឌ្រីមសេរី២០២២ ពណ៌ខ្មៅមិនចាំស្លាកលេខ បានជិះម៉ូតូដឹកអុំស្រីមិនចាំឈ្មោះ ត្រូវជាបងថ្លៃនាងខ្ញុំជនជាតិវៀតណាម ចេញពីផ្ទះនៅឯងក្តាទៅដំបន់ផ្ទះដប់ដើម្បីយកលុយអោយថ្លៃចន្ទីឱ្យកូនស្រីបងរបស់នាងខ្ញុំម្នាក់ទៀត។ មួយសន្ទុះក្រោយម៉ោង៦ ល្ងាចតិច ស្រាប់តែកូនស្រីបងរបស់ខ្ញុំបានតេទូរសព្ទមកនាងខ្ញុំថាចោរប្លន់ស្រីង៉ាបាត់ហើយ ម៉ាក់ឯងមកឱ្យលឿនតិចមក, នាងខ្ញុំប៉ានិងពូសន្តិសុខ កំពុងដេញចោរ ហើយនាងខ្ញុំក៏បានហៅអ្នកភូមិសន្តិសុខជួយតាមរកចោរ ប៉ុន្តែចាប់វាមិនបាននោះទេ។ លុះក្រោយមកទើបសមត្ថកិច្ចចាប់បានតាមក្រោយ។ កូនស្រីរបស់នាងខ្ញុំត្រូវចោរកាប់ត្រូវអាវ និងត្រូវទូរសព្ទខូចអេក្រង់ តែមិនមានរបួសនោះទេ, ចំណែកឯបងថ្លៃខ្ញុំក៏មិនអីនោះដែរ ហើយពេលនោះចោរវាយកតែម៉ូតូមួយគ្រឿងប៉ុណ្ណោះ។ នាងខ្ញុំបានទទួលម៉ូតូវិញហើយ និងមិនទាមទារសំណងអ្វីទៀតឡើយ។

-ជនរងគ្រោះឈ្មោះ [redacted] **ស្រីង៉ា** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ម៉ោង១៨:៣០នាទី កូនស្រីខ្លួនឈ្មោះ [redacted] ស្រីង៉ា អាយុ១៣ឆ្នាំ និងបងថ្លៃស្រីឈ្មោះ [redacted] ធីធី អាយុ ៤១ឆ្នាំបានជិះម៉ូតូម៉ាកហុងដា C125 សេរី2022 ពណ៌ខ្មៅ ពាក់ផ្លាកលេខកំពង់ធំ1Q-4243 លេខតួ និងលេខម៉ាស៊ីន 612372 បានយកលុយទៅឱ្យកូនស្រីខ្លួនឈ្មោះ [redacted] ទីមង៉ុក អាយុ១៧ឆ្នាំ ទិញចន្ទី នៅផ្ទះ១០ខ្នង ដល់ចំណុចខាង ជើងស្ពានអូរធំ ចម្ងាយ១០០ម៉ែត្រ ស្រាប់តែមានជនសង្ស័យប្រុសម្នាក់ អាយុប្រហែល២៨ឆ្នាំជិះម៉ូតូសង់ចាស់កាំ បន្ទះ ពណ៌ខ្មៅ គ្មានផ្លាកលេខ ក្បាលម៉ូតូពណ៌ស គ្មានកាបាំងភ្លើងសុទ្ធ បានធ្វើសកម្មភាពយកដាវចាក់ និងបានប្លន់យក ម៉ូតូនាងជិះចេញទៅបាត់ ហើយបន្សល់ទុកម៉ូតូវានៅកន្លែងកើត ហេតុ។

-សាក្សីឈ្មោះ [redacted] **ផារត** បានឆ្លើយនាពេលសវនាការថា៖ ខ្ញុំឃើញប្តីខ្ញុំបានជិះម៉ូតូមកផ្ទះ ហើយបានដោះដូរអាវម៉ូតូនោះ មានកូន៣នាក់ ដែលនៅតូចៗ។ គាត់ធ្លាប់វាយធ្វើបាបខ្ញុំដែរ និងឱ្យលុយទិញម្ហូប និងឱ្យលុយទិញអីឱ្យកូន។ ខ្ញុំមិនបានជាមួយប្តីខ្ញុំទេ។ ខ្ញុំមិនដែលស្គាល់ឈ្មោះ ស្នា នោះទេ។

-សាក្សីឈ្មោះ [redacted] **សាវ៉ន** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ម៉ោង១៨:០០នាទី មេភូមិឈ្មោះ [redacted] អឿន បានទូរស័ព្ទមកប្រាប់ថាខ្លួនថាមេប៉ុស្តិ៍ក្រយានិងកម្លាំងប្រជា ការពារបីនាក់ឱ្យទៅជួយព្រោះមានចោរប្លន់ម៉ូតូនៅចំណុចខាងជើងស្ពានអូរធំ ហើយខ្លួននិងឈ្មោះ [redacted] សិន និង ឈ្មោះកែន បានជិះម៉ូតូទៅដល់កន្លែងកើតហេតុ បានជួបមនុស្សស្រីរងគ្រោះ និងឃើញម៉ូតូសង់មួយគ្រឿងចាស់ អត់ ខោអាវ(ម៉ូតូជនសង្ស័យ)ជនរងគ្រោះបានប្រាប់ខ្លួនថាចោរប្លន់ជិះម៉ូតូគាត់យកទៅកាត់តាមចម្ការដំឡូងទិសខាងលិចមិនស្គាល់ឈ្មោះទេវាមានដាវមួយចាក់ខ្លួនរហែកខោអាវនិងបែកអេក្រង់ទូរស័ព្ទ ហើយពួកខ្លួនបានជិះម៉ូតូជនល្មើស មកកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលក្រយាតែម្តង ។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted] មី បានឆ្លើយនាពេលសវនាការថា៖ នៅថ្ងៃកើតហេតុ វេលាម៉ោងប្រហែល៥ ល្ងាច មេប៉ុស្តិ៍បានមកប្រាប់មេភូមិឈើទាលជ្រុំ មកប្រាប់ខ្ញុំថាឲ្យទៅមើលគេប្លន់ នៅអូរធំ ដោយគាត់ប្រាប់ថាមេប៉ុស្តិ៍ជាប់ប្រជុំនៅខេត្តកំពង់ធំ ពេលនោះខ្លួនបាននាំគ្នាពីរទៀត ដែលជាប្រជាការពារភូមិទៅមើល ក៏ស្រាប់តែឃើញក្មេងស្រីឈ្មោះ ង៉ា អង្គុយយំ និងឃើញប្រជាពលរដ្ឋអ្នកភូមិទៅជួយច្រើន ហើយពេលនោះ មិនបានឃើញចោរនោះទេ ក្រោយមកក៏ត្រឡប់មកផ្ទះរៀងៗខ្លួនវិញទៅ ។

-សាក្សីឈ្មោះ [redacted] ឡឿន, ឈ្មោះ [redacted] ចក់ និងឈ្មោះ [redacted] សុភា បានឆ្លើយប្រហាក់ប្រហែលគ្នានាដំណាក់កាលចៅក្រមស៊ើបសួរថា៖ ឈ្មោះ ស្នា ដេកឈឺនៅលើកន្ទេល មិនអាចក្រោករួច។ ស្នាត្រូវជាក្មួយខ្លួន ដែលមានមុខរបរ ជាអ្នកធ្វើម្ហូបតាមរោងបុណ្យ។ ក្មួយខ្លួនឈឺតាំងពីមុនកើតហេតុ ១ខែ មុនចូលពន្ធនាគារ ហើយក្មួយខ្លួនស្លូតណាស់ មិនដែលវាយគេទេ។ ពេលនាំទៅពេទ្យ ពេទ្យថាឈឺក្រពះ ពោះវៀន។ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង៩ព្រឹក គឺពិតជាបានសែនមែន ដែលខ្ញុំបាននៅជុំគ្នារហូតដល់ល្ងាច ហើយថ្ងៃដែលគេចាប់ [redacted] ស្នា គឺខ្ញុំបាទមិនបានដឹងទេ ដោយសារខ្ញុំនៅឆ្ងាយពីផ្ទះរបស់ឈ្មោះ ស្នា។ នៅថ្ងៃទី១៣ (មុនថ្ងៃសែន ២ថ្ងៃ) ពេលមកពីធ្វើការចុងភៅ ដែលមានបងធម៌របស់ស្នាបានដឹកឈ្មោះ ស្នាទៅផ្ទះដើម្បីធ្វើពិធីសែនព្រេន ។

-សាក្សីឈ្មោះ [redacted] ថៃ បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២៤ ម៉ោង ០២:០០នាទី ខ្លួនជិះមកលក់បង្អែមនៅដីអតីតយុទ្ធជនភូមិដងក្ដារ (ផ្លូវលំគ្រួសក្រហម) មានមនុស្ស ប្រុសម្នាក់បានហៅខ្លួនទិញបង្អែមប្រហែលអាយុ៣០ឆ្នាំ, សម្បុរសណ្ដែកបាយ ចាក់សាក់លើមុខ សក់ខ្មៅស្រឡូន ពាក់មួកជិពុះទា ពណ៌ខ្មៅ ទុកនៅលើម៉ូតូចាស់គ្មានខោអាវ គម្របភក់គ្មាន ផ្លាកលេខគ្មាន ក្បាលម៉ូតូ ពណ៌ស ។

-សាក្សីឈ្មោះ [redacted] ផាន បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា: នៅឆ្នាំ២០២២ ខ្លួននិងប្ដីបានជិះម៉ូតូទៅរកការងារធ្វើនៅភូមិបាក់ស្នា ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ស្រាប់តែឃើញម៉ូតូចាស់ទុក ចោលផ្លូវលំ ពេលនោះប្ដីខ្លួនបានប្រាប់ឲ្យខ្លួនជិះម៉ូតូទៅមុនទៅ ខ្ញុំនៅលួចម៉ូតូនេះសិន ហើយខ្លួនបានជិះម៉ូតូទៅផ្ទះ ឪពុកខ្លួន នៅភូមិដងក្ដារ ឃុំក្រយាមុន ហើយគាត់លួចម៉ូតូនោះបានយកទៅលក់បានលុយ ៦០០.០០០ (ហុកសិបម៉ឺន) រៀល ឲ្យខ្លួនអ្នកទុក ហើយគាត់ថាម៉ូតូនោះយកទៅលក់នៅជាងជួសជុលម៉ូតូនៅម្ដុំផ្លូវបំបែកច្រមុះជ្រូកកំពង់ថ្ម ។ នៅឆ្នាំ២០២២ មិនចាំថ្ងៃខែខ្លួនបានឃើញប្ដីជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ មកទុកនៅផ្ទះពីរទៅបីថ្ងៃក៏បាត់ម៉ូតូនោះ ខ្លួនបានសួរគាត់ថាជិះម៉ូតូនោះយកទៅណា ហើយគាត់ឆ្លើយថាកុំមាត់នៅឲ្យស្ងៀមស្រេចតែអញ ខ្លួនមិនហ៊ានសួរនាំ ទៀតទេ។ លុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ម៉ោង ១៥.៣០នាទី ខ្លួនបានឃើញប្ដីខ្លួនជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០២២ មិនចាំផ្លាកលេខ មកដល់ផ្ទះដោះក្បាំងម៉ូតូពណ៌ខ្មៅដាក់ក្បាំងម៉ូតូពណ៌សវិញ ដោយក្បាំងទិញទុកនៅ ផ្ទះដូរកង់មុខក្រោយនោះផ្លាកលេខម៉ូតូទុក និងមូលដោះដូរគ្រឿងបន្លាស់ម៉ូតូស្ទើរអស់រួចគាត់យកភួយគ្របជិតប្រហែលពីរបីថ្ងៃក្រោយមកគាត់បានយកម៉ូតូនោះជិះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ សមត្ថកិច្ចបានមកដល់ផ្ទះ និងបានចាប់ឃាត់ប្ដីខ្លួន រួមទាំងដកហូតម៉ូតូនិងសម្ភារៈគ្រឿងបន្លាស់ម៉ូតូ ។

-សាក្សីឈ្មោះ [redacted] ឈាង បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ ជនសង្ស័យ ឈ្មោះ [redacted] សុក ភេទប្រុស អាយុ២៧ឆ្នាំ ពិតជាបានយកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីង៉ា នៅចំណុចខាង ជើងស្ពានអូរធំ ស្ថិតនៅភូមិដងក្ដារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពងធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៨:០០នាទីពិតប្រាកដមែន ។

-សាក្សីឈ្មោះ [redacted] ញឿន បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ រូបខ្លួន និង ឈ្មោះ [redacted] ស្នា មិនជាប់សាច់ញាត្តិនឹងគ្នា នោះទេ គ្រាន់តែរាប់អានជាប្អូនធម៌ ហើយនៅពេលមានរោងការគេហៅខ្ញុំ ធ្វើចុងភៅគឺខ្ញុំតែងតែហៅវាឲ្យមកជួយធ្វើចុងភៅជាមួយខ្ញុំ។ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ ឈ្មោះ [redacted] ស្នា ត្រូវជាប្អូនធម៌របស់ខ្ញុំ បានមកជួយខ្ញុំ



Scanned with CamScanner

បាទធ្វើ ចុងភៅភ្ជាប់ពាក្យឱ្យអ្នកភូមិត្រពាំងសាលា ប៉ុន្តែឈ្មោះ [redacted] ស្លា ឈឺមិនអាចហាន់បន្លែ ហើយមិនឲ្យវាត្រូវភ្លើង ខ្លាចវាលាប់ឈឺទៀត ព្រោះត្រូវមានកម្មវិធីបុណ្យបច្ច័យបួន នៅថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២៤ ជាចូលរោង និងបញ្ចប់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ។ លុះដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤ ខ្ញុំបាទត្រូវជាបងធម៌ បានជូនវាទៅពេទ្យឯកជននៅស្រុកប្រាសាទសំបូរ ដើម្បីគេស្ទួឈាមពិនិត្យមើលព្រោះវាក្ដៅខ្លួន រហូតដល់ព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២៤ ខ្ញុំបាទក៏បាននាំឈ្មោះ [redacted] ស្លា ចេញពីពេទ្យមកស្នាក់នៅផ្ទះវិញ ហើយ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ ឈ្មោះ [redacted] ស្លា មិនបានទៅកម្មវិធីបុណ្យបច្ច័យបួន នោះទេ ដោយទុកវានៅនឹងផ្ទះរបស់ខ្ញុំ ហើយព្រឹកនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ក៏វាមិនបានទៅដែរ រហូតដល់វេលាម៉ោង៩ព្រឹក ទើបខ្ញុំបាទជិះម៉ូតូដឹកឈ្មោះ [redacted] ស្លា ទៅផ្ទះរបស់វានៅភូមិដងក្ដារទៅដល់ផ្ទះរបស់វាប្រហែលម៉ោង១០:៣០នាទីព្រឹក ហើយពេល នោះវាក្អួត ហើយនិងក្ដៅខ្លួនខ្លាំង ហើយអ្នកផ្ទះមិនមានអ្នកណានៅនោះទេទៅចម្ការអស់ហើយ ពេលនោះខ្លួនក៏បាន ជូតទឹកឲ្យវាត្រជាក់ខ្លួនសិន ទើបខ្ញុំត្រឡប់មកផ្ទះវិញនៅវេលាម៉ោង៣រសៀល។ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ឈ្មោះ [redacted] ស្លា បានផាតតាមហ្វេសបុកប្រាប់ខ្ញុំថាខ្ញុំសែនហើយបង ហើយវាបានផតរូបផតវាដែលមានរូបភ្នួរសេរ៉ូម ចំនួនពីរកំប្លោក ។ ចាប់តាំងពីឈ្មោះ [redacted] ស្លា ទៅផ្ទះរបស់វា ហើយវាមិនដែលមកផ្ទះខ្ញុំវិញនោះទេ។ ខ្ញុំបាទសុំ បញ្ជាក់ថា: នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ឈ្មោះ [redacted] ស្លា មិនបានមកធ្វើចុងភៅនៅ ប្រាសាទសំបូរ ជាមួយខ្ញុំនោះ ទេ,ព្រោះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ឈ្មោះ [redacted] ស្លា ត្រូវសែន ខ្លាចខុសលោកតា ឬត្រូវអំពើរបស់គេ, ហើយខ្លួនក៏មិន ដែលស្គាល់ឈ្មោះ [redacted] សុក នោះទេ ។

-សាក្សីឈ្មោះ [redacted] **ទិត** បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ នៅឆ្នាំ២០២៣ ខ្លួនធ្លាប់ ឃើញមនុស្សប្រុសម្នាក់ មិនស្គាល់ឈ្មោះតែចំណាំមុខ អាយុប្រហែល២៨ឆ្នាំ រស់នៅភូមិទក់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បានប្រពន្ធអ្នកភូមិដងក្ដារ ធ្លាប់ជិះម៉ូតូសង់ចាស់ឡើងតែមឆ្នាំ២០២២ ក្បាលម៉ូតូពណ៌ស ផ្លាកលេខគ្មាន បានមកលេងបាល់ទះ នៅផ្ទះរបស់ខ្លួន មានចាក់សាក់ដៃជើងនិងដើមទ្រូង ។

-សាក្សីឈ្មោះ [redacted] **គេន** បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនបានជិះម៉ូតូឌុបបងប្អូនទៅលេងផ្ទះបងប្អូន នៅដីអតីតយុទ្ធជននៅភូមិដងក្ដារ ឃុំក្រយា មកដល់ផ្លូវមីលីហេង ខាងជើងស្ពានអូរធំ ចម្ងាយប្រហែល១០០ម៉ែត្រ ស្រាប់តែឃើញម៉ូតូ០១គ្រឿងចាស់ ក្បាលស គ្មានខោអាវ គ្មានផ្លា កលេខ បញ្ឈរទុកទទឹងចិញ្ចើមផ្លូវ ខ្លួនបានស្រែកសួរថាតើម៉ូតូអ្នកណាទុកកណ្ដាលផ្លូវ,ភ្លាមនោះមានមនុស្សស្រីពីរ នាក់ដើរចេញពីចម្ការចន្ទីស្រែកថាជួយផង១ខ្លួនបាននិយាយថាចាំខ្លួនជិះម៉ូតូដេញតាមតែដឹហ៊ុយពេក ក៏ត្រឡប់មក វិញ ។

-មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] **សារិទ្ធ** បានឆ្លើយនាដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី១៦ ឆ្នាំ២០២៤ មានករណីលួចមានស្ថានទម្ងន់ទោសកើតឡើងដែលប្រព្រឹត្តឡើងដោយជនសង្ស័យឈ្មោះ [redacted] សុក ។ បន្ទាប់ពីកើតហេតុកម្លាំង សមត្ថកិច្ចបានចុះស្រាវជ្រាវឃាត់ខ្លួនបានជនសង្ស័យចំនួន ០១នាក់ឈ្មោះ [redacted] សុក និង វត្ថុតាងម៉ូតូឌ្រីមសង់របស់ជនរងគ្រោះ ដែលជនសង្ស័យបានយកទៅ ប្តូរអាវ និងដោះស្លាកលេខចេញពណ៌ស ដែលជនសង្ស័យបានដោះដូរខោអាវ យើងបានពិនិត្យលេខម៉ាស៊ីន គឺពិតជាម៉ូតូដែលប្លន់ពីជនរងគ្រោះពិតមែន។ចំនួន០១គ្រឿង និងដាវចំនួន០១ដើម។ ជនសង្ស័យបានសារភាពថាខ្លួនបានធ្វើ សកម្មភាពកាប់ប្លន់យកម៉ូតូមានគ្នាចំនួន០២នាក់ ដោយម្នាក់ទៀតឈ្មោះ [redacted] ស្លា។ បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏បាន ស្រាវជ្រាវបន្តទៅឃាត់ខ្លួនបានឈ្មោះ [redacted] ស្លា ម្នាក់ទៀត។ បន្ទាប់ពីសាកសួររួចកម្លាំងសមត្ថកិច្ចក៏បានកសាង សំណុំរឿងមកតុលាការតែម្តង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំដូចតទៅ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ, តាមការស្ដាប់ចម្លើយរបស់ជនជាប់ចោទ, តាមការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, តាមការស្ដាប់ចម្លើយរបស់ជនរងគ្រោះ តាមការស្ដាប់ចម្លើយរបស់សាក្សី, តាមការស្ដាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការពិនិត្យភស្តុតាងពាក់ព័ន្ធដែលមាន

នៅក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា៖ ពិតជាមានករណី **"លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ជាវ)"** ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **សុក** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្ដារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ និងគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] **ស្លា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ដូចនេះតំណាងអយ្យការ ប្ដឹងសុំ ឱ្យឈ្មោះ [redacted] **ស្លា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ រួចខ្លួន ពីបទចោទ ពីបទ៖ **"លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ជាវ)"** ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្ដារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុក បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមគោរពអង្គសវនាការទាំងមូល ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុក ធ្វើការស្នើសុំដល់ចៅក្រមជំនុំជម្រះ ក៏ដូចជាតំណាងអយ្យការ មេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីខ្ញុំបាទផង ដោយសារកូនក្ដីខ្ញុំបាទបានសារភាព និងទទួលស្គាល់កំហុសរបស់ខ្លួនហើយដែរ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស្លា បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមគោរពអង្គសវនាការទាំងមូល ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស្លា ធ្វើការស្នើសុំដល់ចៅក្រមជំនុំជម្រះ ក៏ដូចជាតំណាងអយ្យការ មេត្តាសម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ ពីបទ៖ **"លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ជាវ)"** ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្ដារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ដោយសារកូនក្ដីរបស់ខ្លួនពិតជាមិនបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **សុក** សំណូមពរតុលាការ៖ សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួន។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលនាសវនាការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុក

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្លា

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយ និងអំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្ដាប់សេចក្តីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុក

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានាក្នុងសំណុំរឿង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សាលាដំបូងខេត្តកំពង់ធំ



Scanned with CamScanner

## សំអាងហេតុ:

-យល់ឃើញថា: តុលាការបានទទួលបណ្តឹងតាមដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ: ៣០១០/២០២៤ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ដែលសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] សុភ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ស្លា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មកតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តកំពង់ធំ និងសំណុំរឿងព្រហ្មទណ្ឌលេខ: ២៧២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, វត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនទាក់ទិនក្នុងសំណុំរឿង ទៅតុលាការដើម្បីជំនុំជម្រះ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា: ឆ្លងតាមការសួរដេញដោលក្នុងសវនាការ, តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទ, តាមការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, តាមការស្តាប់ចម្លើយរបស់ជនរងគ្រោះ, តាមការស្តាប់ចម្លើយរបស់សាក្សី, តាមការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌, រួមទាំងការពិនិត្យភស្តុតាងជាឯកសារនៅក្នុងសំណុំរឿង និងវត្ថុតាងពាក់ព័ន្ធ អាចឱ្យតុលាការជឿជាក់បានថា: កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ពិតជាមានអង្គហេតុនៃបទល្មើស "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុភ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។ ចំណែកអង្គហេតុនៃបទល្មើស "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស្លា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ គឺតុលាការយល់ឃើញថា មិនមានភស្តុតាងដាក់គ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ នេះ ឡើយ គប្បីតុលាការសម្រេចឱ្យឈ្មោះនេះ រួចផុតពីបទចោទ។

-យល់ឃើញថា: សំបុត្រមរណភាពលេខ ៣១ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ របស់ឈ្មោះ [redacted] ស្លា បានបញ្ជាក់ថាឈ្មោះ នេះ បានទទួលមរណៈភាពកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៤ ហើយ គប្បីតុលាការសម្រេចពិចារណា។

-យល់ឃើញថា: ទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុភ** ជាបទល្មើស៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] **សុភ** ជានីតិជន និងមិនមានភស្តុតាង ឬសញ្ញាណណាដែលបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីទេ ហេតុដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងរបៀបរៀបរយក្នុងសង្គម។

-យល់ឃើញថា: មានភស្តុតាងដាក់បន្ទុក និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទដែលអាចឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សុភ** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា: តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សុភ** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិដងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមី



Scanned with CamScanner

នា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ និងប្តឹងសុំ ឱ្យឈ្មោះ [redacted] **ស្លា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ រួចខ្លួន ពីបទចោទ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពាន អូរធំ ប្រហែល១០០ម៉ែត្រ ភូមិអងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

**-យល់ឃើញថា:** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ភូឡង់** បានបញ្ជាក់ប្រាប់មុខអង្គសវនាការទាំងមូលថា ខ្លួនមិនទាមទារសំណងអ្វីឡើយ គប្បីតុលាការមិនពិចារណាលើសំណងរដ្ឋប្បវេណី។

**-យល់ឃើញថា:** តាមចម្លើយបញ្ជាក់របស់ជនរងគ្រោះថាឃើញតែមនុស្សប្រុសម្នាក់ ជាអ្នកធ្វើសកម្មភាពប្លន់ ដោយទុក ម៉ូតូជននោះចោលហើយជិះម៉ូតូរបស់ខ្លួនចេញទៅ។

**-យល់ឃើញថា:** តាមចម្លើយរបស់ឈ្មោះ សិន ផាន ដែលជាប្រពន្ធរបស់ឈ្មោះ [redacted] សុក ថាខ្លួនមិនស្គាល់ ឬជួបឈ្មោះ [redacted] ស្លា នោះទេ។

**-យល់ឃើញថា:** តាមចម្លើយជនជាប់ចោទទាំងពីររូប ចម្លើយជនរងគ្រោះ និងចម្លើយសាក្សី បញ្ជាក់ឱ្យតុលាការជឿថា ជនជាប់ចោទ [redacted] សុក គឺបានធ្វើសកម្មភាពប្លន់យកម៉ូតូ ពីជនរងគ្រោះ តែម្នាក់ឯងប៉ុណ្ណោះ គឺពុំមានការចូលរួមពីឈ្មោះ [redacted] ស្លា ឡើយ។

**-យល់ឃើញថា:** តាមចម្លើយរបស់ឈ្មោះ [redacted] ស្លា បានបញ្ជាក់ថាខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] សុក នោះទេ ហើយថ្ងៃកើតហេតុ ខ្លួនបានទៅធ្វើម្ហូបការឱ្យគេនៅប្រាសាទសំបូរ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤ ដូច្នេះ គប្បីតុលាការសម្រេចឱ្យឈ្មោះ [redacted] ស្លា រួចខ្លួនពីបទចោទ ពីបទ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិអងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្ម-ទណ្ឌ។

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

**<u>១-ផ្តន្ទាទោស៖</u>**

**១.១**-ឈ្មោះ [redacted] **សុក** ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) ដាក់ពន្ធនាគារ កំណត់រយៈពេល **០៥ (ប្រាំ) ឆ្នាំ** ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល១០០ម៉ែត្រ ភូមិអងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យឈ្មោះ [redacted] **ស្លា** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) រួចផុតពីបទចោទ ពីបទ៖ "**លួចមានស្ថានទម្ងន់ទោស (ប្រើប្រាស់ដាវ)**" ប្រព្រឹត្តនៅចំណុចផ្លូវលំគ្រួសក្រហម ខាងជើងស្ពានអូរធំ ប្រហែល ១០០ម៉ែត្រ ភូមិអងក្តារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សុក** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ភូឡង់**។



Scanned with CamScanner

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

| **បានឃើញ** | **"បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម"** |
|---|---|
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | ថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨<br>កំពង់ធំ, ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤<br>**ក្រឡាបញ្ជីសវនាការ** |
| [redacted] | [redacted] |



Scanned with CamScanner